ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ស្ពឺ**
សំណុំរឿងព្រហ្មទណ្ឌលេខ: ៦៣៧
ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០
សាលក្រមព្រហ្មទណ្ឌលេខ:៥៣(ក)
ចុះថ្ងៃទី០៤ ខែ មករា ឆ្នាំ ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកំពង់ស្ពឺ បានបើកសវនាការជាសាធារណៈក្នុងសាលសវនាការ នៃ សាលាដំបូងខេត្តកំពង់ស្ពឺ នៅថ្ងៃទី១៥ ខែ ធ្នូ ឆ្នាំ២០២០ វេលាម៉ោង៩ និង០០ នាទី ព្រឹក ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

ឯកឧត្តម [redacted] ជាប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

**មេធាវី ឬអ្នកការពារក្តី**

លោក [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ហៅ ប៊ុ ។

**ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលើជនជាប់ចោទ ៖**

១.ឈ្មោះ [redacted] **នុន ហៅ លេញ** ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករសំណង់ កំរិតវប្បធម៌ថ្នាក់ទី៧ (មិនចេះអក្សរ) ទីកន្លែងកំណើត និង ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ជឿ (រ) ម្តាយឈ្មោះ [redacted] លី (រ) ប្រពន្ធឈ្មោះ [redacted] ចិន្តា មានកូន០២នាក់ ទោសពីមុនគ្មាន (ឃុំខ្លួនលេខ: ៦២១ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០) ។

២.ឈ្មោះ [redacted] **ចំរើន ហៅម៉ាប់** ភេទប្រុស អាយុ៣០ឆ្នាំ ឬ កើតឆ្នាំ១៩៩០ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ កំរិតវប្បធម៌ថ្នាក់ទី១២ ទីកន្លែងកំណើត និង ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] មឺន (រ) ម្តាយឈ្មោះ [redacted]

គឿន (រ) ប្រពន្ធឈ្មោះ [redacted] ចិន្តា មានកូន០១នាក់ ទោសពីមុនគ្មាន (ឃុំខ្លួនលេខ:៦២២ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០) ។

**៣.ឈ្មោះ [redacted] ប៊ុនធឿន ហៅ ប៊ុ** ភេទប្រុស អាយុ២៤ឆ្នាំ ឬ កើតឆ្នាំ១៩៩៦ ជនជាតិខ្មែរ មុខរបរធ្វើសំណង់ កំរិតវប្បធម៌ថ្នាក់ទី៤ (មិនចេះ) ទីកន្លែងកំណើត និង ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ ថា (រ) ម្តាយឈ្មោះ [redacted] អូន នៅលីវ ទោសពីមុនគ្មាន (ឃុំខ្លួនលេខ: ៦២៣ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០) ។

**៤.ឈ្មោះ [redacted] ជាតិ** ភេទប្រុស អាយុ២៥ឆ្នាំ ឬ កើតឆ្នាំ១៩៩៥ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ចុន (...) ម្តាយឈ្មោះ [redacted] យ៉ុន (....) នៅលីវ ទោសពីមុនគ្មាន (ក្រៅឃុំ) ។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ: រក្សាទុក ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិអូររំចេក ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ ,៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៩៨៤២ ជសព/២០ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ។

**-បានឃើញ** ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ១៨៧៤ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ ។

**-បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ១៩១២ ជចជ.រប/២០ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ

.កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១៤និង៥០នាទី នៅចំណុចភូមិអូររំចេក ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នៅអំឡុងឆ្នាំ២០១១ ដល់ឆ្នាំ២០២០ មានករណី រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មួយបានកើតឡើងដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] នុន ,ឈ្មោះ [redacted] ចំរើន ,ឈ្មោះ [redacted] ប៊ុនធឿន ហៅ ប៊ុ , ឈ្មោះ [redacted] ជាតិ បានធ្វើសកម្មភាពរក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ពិតប្រាកដមែន ។

## នាពេលសវនាការ

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] នុន ហៅ លេញ បានឆ្លើយសារភាពថាៈ ខ្លួនអាចឆ្លើយដោយខ្លួនឯងបានដោយមិនចាំបាច់មានមេធាវីការពារទេ ។ ខ្លួនចាប់ផ្តើមប្រើប្រាស់គ្រឿងញៀន នៅក្នុងឆ្នាំ២០១៨ បើគិតជាលើក គឺច្រើនរាប់មិនអស់ដោយគ្រឿងញៀនទាំងនោះខ្លួនបានទិញពីឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ ភេទប្រុស អាយុប្រហែល ៣០ឆ្នាំ នៅភូមិអូររំចេក ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទិញក្នុង១លើកចំនួន ០១កញ្ចប់ ក្នុងតម្លៃចំនួន ២០០០០រៀល



Scanned with CamScanner

ទៅចំនួន៤០០០០ រៀល និងបានយកទៅប្រើប្រាស់នៅក្នុងព្រៃខាងជើងភូមិជាមួយប្អូនជីដូនមួយឈ្មោះ ដា ភេទប្រុស អាយុប្រហែល ១៨ឆ្នាំ នៅភូមិអូររំចេក ឃុំសែនដី ស្រុកសំពៅងទង និងឈ្មោះ មោក ភេទប្រុស អាយុប្រហែល ២៤ឆ្នាំ នៅភូមិអូររំចេក ឃុំសែនដី ស្រុកសំពៅងទង ។

ដោយកន្លងមកឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ ធ្លាប់បានប្រើខ្លួនឲ្យយកគ្រឿងញៀនទៅលក់ឲ្យគេបានប្រហែល៨លើកដោយក្នុង០១កញ្ចប់ ក្នុងតម្លៃចំនួន ៣០០០០រៀល ។ នៅពេលដែលខ្លួនលក់គ្រឿងញៀនអស់ឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ បានឲ្យលុយមកខ្លួនចំនួន ៣០០០០ រៀល ជាឈ្នួលដែលខ្លួនបានលក់គ្រឿងញៀនឲ្យគេនោះ ។

នៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០២០ វេលាម៉ោងប្រហែល ៣រសៀល ឈ្មោះ [redacted] ចំរើន ហៅម៉ាប់ បានប្រើខ្លួនឲ្យយកគ្រឿងញៀនចំនួន ០២កញ្ចប់ ក្នុងតម្លៃ៥០០០០ រៀល ទៅលក់ឲ្យគេនៅទំនប់ខាងជើងភូមិអូររំចេក ។ នៅពេលខ្លួនជិះម៉ូតូយកគ្រឿងញៀនទៅលក់ឲ្យគេស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួននិងបានដកហូតម៉ូតូ ០១គ្រឿង ម៉ាកគប់ជ្រុង ពណ៌ទឹកប៊ិក (ចាស់) ដែលជារបស់ឪពុកឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ ។

ខ្លួនទើបតែចាប់ផ្តើមលក់គ្រឿងញៀនឲ្យឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ បានចំនួន ៨លើកក្នុងខែមិថុនា នេះតែប៉ុណ្ណោះ ។

សំណូមពរ សុំឲ្យតុលាការជួយបន្ធូរបន្ថយទោស ខ្លួនបានដឹងពីកំហុសរបស់ខ្លួនហើយ ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ បានឆ្លើយសារភាពថាៈ ខ្លួនអាចឆ្លើយដោយខ្លួនឯងបានដោយមិនចាំបាច់មានមេធាវីការពារទេ ។ ខ្លួនសូមមិនទទួលស្គាល់ចម្លើយនៅសមត្ថកិច្ច ពីព្រោះថាចម្លើយនោះខ្លួនបានឆ្លើយ ដោយមានការបង្ខិតបង្ខំ ។

កាលពីថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ៣រសៀល ខ្លួនកំពុងដេកលេងនៅផ្ទះស្រាប់តែមានសមត្ថកិច្ច ចុះមកឃាត់ខ្លួនតែម្តង ដោយបានឃាត់ឈ្មោះ [redacted] នុន មុនខ្លួនគេទើបមកឃាត់ខ្លួនទៀត ។ នៅពេលឃាត់ខ្លួនសមត្ថកិច្ចឆែកឆេររកឃើញជញ្ជីងថ្លឹងគ្រឿងញៀនចំនួន ០១គ្រឿង , ទូរស័ព្ទម៉ាកវីវ៉ូ (ថ្មី ) និង ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន និង ពុំមានគ្រឿងញៀននោះទេ។ រួចមកសមត្ថកិច្ចបានបញ្ជូនខ្លួនមកស្នងការនគរបាលខេត្តកំពង់ស្ពឺ ធ្វើតេស្តទឹកនោមរកសារធាតុញៀន ឃើញមានសារធាតុញៀន ។

ខ្លួនចេះប្រើប្រាស់គ្រឿងញៀនតាំងពីឆ្នាំ២០១៥ មកម្ល៉េះ ដែលទិញម្តងក្នុងតម្លៃចាប់ពី ៥០០០០ រៀល ដល់ចំនួន ១០.០០០០ រៀល ទៅទិញពីឈ្មោះ [redacted] ឈុនឡេង រស់នៅភូមិដូនទ្រើ ឃុំលាំងគ្រើល ស្រុកសំពៅងទង ខេត្តកំពង់ស្ពឺ រួចយកមកប្រើប្រាស់ជាមួយឈ្មោះ [redacted] នុន ហៅ លេញ និង ឈ្មោះ [redacted] រ៉ាត ភេទប្រុស អាយុប្រហែល ៣១ឆ្នាំ , ឈ្មោះ រដ្ឋា ភេទប្រុស អាយុ ៣០ឆ្នាំ , ឈ្មោះ ណាង រស់នៅភូមិដូនទ្រើ ទាំងអស់ ។ រហូតដល់ឆ្នាំ ២០១៩ ខ្លួនទិញគ្រឿងញៀនម្តងក្នុងតម្លៃចំនួន ៥០.០០០០៛ (ហាសិបម៉ឺន) រៀល ដល់ចំនួន ៦០.០០០០៛ (ហុកសិបម៉ឺន) រៀល ដែលបានចូលលុយគ្នាជាមួយឈ្មោះ ណាង , ឈ្មោះ [redacted] រ៉ាត និង ឈ្មោះ

[redacted] នុន ហៅ លេញ ក្នុងម្នាក់ក្នុងតម្លៃចំនួន ១០.០០០០៛ (ដប់ម៉ឺន) ទៅចំនួន ១៥.០០០០៛ (ដប់ប្រាំម៉ឺន) រៀល ដើម្បីយកមកប្រើប្រាស់រួមគ្នា រួចសល់បានរំលែកចែកគ្នា ។ ចំពោះជញ្ជីងថ្លឹងគ្រឿងញៀន ខ្ញុំនរើសដែលឃើញគេបោះចោល ហើយពេលរើសនោះវាគឺខូចបាត់ទៅហើយ ។ ខ្ញុំនមិនធ្លាប់ប្រើឈ្មោះ [redacted] នុន និង ឈ្មោះ [redacted] ប៊ុនធឿន យកគ្រឿងញៀនឲ្យគេនោះទេ ។ ចំពោះឈ្មោះ [redacted] ជាតិ , ឈ្មោះ [redacted] រី , ឈ្មោះ ចិត្ត , ឈ្មោះ ថ្នោក , ឈ្មោះ រើន , ឈ្មោះ ថង , ឈ្មោះ ដា , ឈ្មោះ មកខ្ញុំនមិនស្គាល់នោះទេ ។

សំណូមពរ ខ្ញុំនសុំឲ្យតុលាការជួយបន្ធូរបន្ថយទោស ខ្ញុំនបានដឹងពីកំហុសហើយ ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ហៅ ប៊ុ បានឆ្លើយសារភាពថា៖ ខ្ញុំនចាប់ផ្តើមប្រើប្រាស់គ្រឿងញៀន នៅក្នុងឆ្នាំ២០១១ បើគិតជាលើក គឺច្រើនរាប់មិនអស់ដោយគ្រឿងញៀនទាំងនោះខ្ញុំនបានទិញពីអ្នកមិនស្គាល់ឈ្មោះ នៅភ្នំពេញ ចំនួន ៤ទៅ ៥លើក និងទិញពីឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ ភេទប្រុស អាយុប្រហែល ៣០ឆ្នាំ នៅភូមិអូររំចេក ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទិញក្នុង ១លើក ០១កញ្ចប់ ក្នុងតម្លៃចំនួន ២០០០០រៀល និងបានយកទៅប្រើប្រាស់នៅក្នុងព្រៃខាងត្បូងផ្ទះជាមួយមិត្តភក្តិ ១.ឈ្មោះ [redacted] ជាតិ ភេទប្រុស អាយុប្រហែល ២៩ឆ្នាំ , ២.ឈ្មោះ [redacted] រី ភេទប្រុស អាយុប្រហែល ២៤ឆ្នាំ , ៣.ឈ្មោះ ចិត្ត ភេទប្រុស អាយុប្រហែល ២៥ឆ្នាំ អ្នកទាំង០៣នាក់ នៅភូមិព្រៃជ្រាវ ឃុំសែនដី ស្រុកសំរោងទង ។ ចំពោះឈ្មោះ [redacted] នុន ហៅ លេញ នៅភូមិអូររំចេក ឃុំសែនដី ស្រុកសំរោងទង ខ្ញុំនស្គាល់តែមិនដែលបានប្រើប្រាស់ជាមួយនោះទេ កន្លងមក ឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ មិនធ្លាប់បានប្រើខ្ញុំនឲ្យយកគ្រឿងញៀនទៅលក់ឲ្យគេនោះទេ ។

នៅថ្ងៃទីមិនចាំ ខែមិនចាំ ឆ្នាំ ២០២០ វេលាម៉ោងប្រហែល ៩ព្រឹក ពេលខ្ញុំនកំពុងនៅផ្ទះស្រាប់តែមានសមត្ថកិច្ចមកធ្វើការឃាត់ខ្ញុំនតែម្តង និង ធ្វើការឆែកឆេររកពុំឃើញមានអ្វីឡើយ ព្រោះគ្រឿងញៀននោះពួកខ្ញុំនជក់អស់ពីយប់មុនពេលសមត្ថកិច្ចឃាត់ខ្ញុំន ។ ខ្ញុំនពុំធ្លាប់ជួញដូរគ្រឿងញៀននោះទេ គ្រាន់តែប្រើប្រាស់ប៉ុណ្ណោះ ។ ខ្ញុំនមិនធ្លាប់ចូលលុយគ្នាទិញគ្រឿងញៀនជាមួយឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ នោះទេ ។

សំណូមពរ សុំឲ្យតុលាការជួយបន្ធូរបន្ថយទោសខ្ញុំនបានដឹងពីកំហុសរបស់ខ្ញុំនហើយ។

**<u>សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបន្ទាប់ពីចប់ការសួរដេញដោល</u>**

+តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានទោសថា៖ ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ នាពេលសវនាការនេះរួចមកឃើញថា: កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ នៅចំណុចភូមិអូររំចេក ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និង អំឡុងឆ្នាំ២០១១ ដល់ឆ្នាំ ២០២០ នៅខេត្តកំពង់ស្ពឺ មានករណី រក្សាទុក ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មួយបានកើតឡើងដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] នុន ហៅ លេញ , ឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ , ឈ្មោះ [redacted] ប៊ុនធឿន ហៅ ប៊ុ និង ឈ្មោះ [redacted] ជាតិ ធ្វើសកម្មភាព



Scanned with CamScanner

រក្សាទុកនិងជួញដូរដោយខុសច្បាប់នូវសារធាតុញៀននិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ពិតប្រាកដមែន ។

មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកទៅលើជនជាប់ចោទ ខាងលើ ពីបទៈ រក្សាទុក ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៤០ និង មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ដូច្នេះតំណាងអយ្យការនៅតែតម្កល់ដីកាសន្និដ្ឋានស្ថាពរ ទុកជាបានការពេញទាំងមូល សូមលោកចៅក្រមសម្រេចតាមច្បាប់ ។

+សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទថាៈ ក្រោយពីបានស្តាប់ចម្លើយ នាពេលសវនាការនេះរួចមកឃើញថា ពិតជាមានអង្គហេតុកើតឡើង កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ ប្រព្រឹត្តនៅភូមិអូររំចេក ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។ តាមចម្លើយសួរដេញដោលមកលើកូនក្តីខ្ញុំឈ្មោះ [redacted] ប៊ុនធឿន ហៅ ប៊ុ ឃើញថាពុំមានជាប់ពាក់ពន្ធ័ក្នុងករណី រក្សាទុក ឬ ជួញដូរ ដោយខុសច្បាប់នូវសារធាតុញៀន ដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ គឺកូនក្តីខ្ញុំ គ្រាន់តែបានប្រើប្រាស់គ្រឿងញៀនប៉ុណ្ណោះ ។ ជាក់ស្តែងនៅថ្ងៃកើតហេតុនោះ កូនក្តីខ្ញុំ គ្រាន់តែបានទៅទិញគ្រឿងញៀន ពីឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ បានចំនួន ០១ កញ្ចប់តូច ក្នុងតម្លៃចំនួន៣០០០០រៀល យកមកប្រើប្រាស់ម្នាក់ឯង នៅពេលយប់ដើរចាប់កង្កែប ។ ពេលមកដល់ផ្ទះវិញ ទើបសមត្ថកិច្ចចាប់ឃាត់ខ្លួន ដោយឆែកឆេរពុំមានគ្រឿងញៀននោះទេ ហើយមានភាពស្របគ្នាទៅនឹងចម្លើយរបស់ឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ និង ឈ្មោះ [redacted]នុន គឺកូនក្តីខ្ញុំពុំមានជាប់ពាក់ពន្ធ័ជួញដូរគ្រឿងញៀន នោះទេ សូមលោកចៅក្រមកែប្រែបទចោទ មកជាបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយក្តីអនុគ្រោះ ។

**សំដីចុងក្រោយរបស់ជនជាប់ចោទៈ**

-ឈ្មោះ [redacted] នុន ហៅ លេញ , ឈ្មោះ [redacted]ចំរើន ហៅ ម៉ាប់ និង ឈ្មោះ [redacted] ប៊ុនធឿន ហៅ ប៊ុ សុំឲ្យតុលាការជួយបន្ធូរបន្ថយទោសឲ្យខ្លួនផង ។

.ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

.ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

.ក្រោយពីបានពិនិត្យសំណុំរឿងឯកសារ និង ភស្តុតាងនានា

.ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

.ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

# <u>សាលាដំបូងខេត្តកំពង់ស្ពឺ</u>

## យល់ឃើញថា

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] នុន ហៅ លេញ , ឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ , ឈ្មោះ [redacted] ប៊ុនធឿន ហៅ ប៊ុ និង ឈ្មោះ [redacted] ជាតិ កាលពីថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០២០ ប្រព្រឹត្តនៅភូមិអូររំចេក ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និង នៅក្នុង អំឡុងឆ្នាំ២០១១ ដល់ ឆ្នាំ២០២០ ពិតជាបានប្រព្រឹត្តអំពើ ដែលរំលោភលើមាត្រា ៤០ ,៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី ។

## យល់ឃើញថា

-អំពើ និង សកម្មភាពរបស់ជនជាប់ចោទឈ្មោះ ដឹម នុន ហៅ លេញ , ឈ្មោះ [redacted] ប៊ុនធឿន ហៅ ប៊ុ , ឈ្មោះ [redacted] ជាតិ ដោយកន្ទងមកធ្លាប់បានទិញគ្រឿងញៀនពីឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ យកទៅប្រើប្រាស់ដោយក្នុង០១ កញ្ចប់ ក្នុងតម្លៃចំនួន ៣០០០០រៀល ហើយ ឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ បានឲ្យគ្រឿងញៀនមកឈ្មោះ [redacted] នុន ហៅ លេញ លក់បន្តទៅឲ្យអ្នកដទៃផ្សេងទៀត។ ដែលហេតុការណ៍កើតឡើងកាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ នៅពេលដែលសមត្ថកិច្ចចុះបង្ក្រាបជាក់ស្តែង និង បានធ្វើការចាប់ឃាត់ខ្លួនឈ្មោះ [redacted] នុន ហៅ លេញ គឺបានឆែកឆេរឃើញគ្រឿងញៀន ០២កញ្ចប់ ដកហូតពីឈ្មោះ [redacted] នុន ហៅ លេញ តែម្តង ចំណែកឈ្មោះ [redacted] ប៊ុនធឿន ហៅ ប៊ុ បានទិញគ្រឿងញៀនពីឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ ចំនួន០១ កញ្ចប់ ក្នុងតម្លៃចំនួន ៣០០០០ រៀល យកមកប្រើប្រាស់តែម្នាក់ឯងអស់ហើយ និង ដោយកន្ទងមកឈ្មោះ [redacted] នុន ហៅ លេញ ធ្លាប់បានយកគ្រឿងញៀនទៅឲ្យគេ ដោយ ឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ ជាអ្នកប្រើផងដែរ គប្បីតុលាការលើកយកអំពើ និង សកម្មភាពរបស់ជនជាប់ចោទទាំងនោះមកធ្វើការពិនិត្យពិចារណាក្នុងការសម្រេច ។

## យល់ឃើញថា

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] នុន ហៅ លេញ ,ឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ , ឈ្មោះ [redacted] ប៊ុនធឿន ហៅ ប៊ុ , ឈ្មោះ [redacted] ជាតិ ពីបទ រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តឡើងកាលពីថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០២០ នៅភូមិអូររំចេក ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និង អំឡុងឆ្នាំ២០១១ ដល់ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសមាត្រា ៤០ , ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យញៀន គប្បីតុលាការពិនិត្យពិចារណាក្នុងការសម្រេចសេចក្តី ។

## យល់ឃើញថា

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន នាពេលសវនាការនេះថាសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរទុកជាបានការពេញទាំងមូល សូមតុលាការសម្រេចផ្តន្ទាទោសទៅតាមច្បាប់ គប្បីតុលាការពិនិត្យពិចារណាក្នុងការសម្រេចសេចក្តី។



Scanned with CamScanner

**យល់ឃើញថា**

.មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ហៅ ប៊ិ បានសុំឲ្យតុលាការធ្វើការកែប្រែបទចោទប្រកាន់ ពីបទ រក្សាទុក ឬ ជួញដូរ ដោយខុសច្បាប់នូវសារធាតុញៀន មកជាបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន គប្បីតុលាការពិនិត្យពិចារណាក្នុងការសម្រេចសេចក្តី ។

**យល់ឃើញថា**

-ជនជាប់ចោទឈ្មោះ [redacted] នុន ហៅ លេញ ,ឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ , ឈ្មោះ [redacted] ប៊ុនធឿន ហៅ ប៊ិ ,ឈ្មោះ [redacted] ជាតិ ជាមនុស្សដែលមានការយល់ដឹងបានតិចតួច ហើយការប្រព្រឹត្តពុំមានលក្ខណៈធ្ងន់ធ្ងរទេ (មិនបង្ក គ្រោះថ្នាក់ដល់សង្គម) សណ្តាប់ធ្នាប់ និង របៀបរៀបរយសារធារណៈ គប្បីតុលាការលើកយកស្ថានសំរាលខ្លះមកធ្វើការពិចារណាក្នុងការសម្រេចសេចក្តី ។

**យល់ឃើញថា**

-តាមកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺវត្ថុតាងរួមមាន៖

១-ទូរស័ព្ទដៃមួយគ្រឿងម៉ាក VIVO ពណ៌ក្រហមចំនួន០១គ្រឿង

២- ទូរស័ព្ទដៃមួយគ្រឿងម៉ាក HVAWEI ពណ៌ទឹកប្រាក់ចំនួន០១គ្រឿង

៣-ជញ្ជីងថ្លឹងគ្រឿងញៀនចំនួន០១គ្រឿង

៤-ម៉ូតូម៉ាកគប់ជ្រុងពណ៌ទឹកប៊ិច ពាក់ស្លាកលេខ ជ.០២៦៩ ភព១ ចំនួន០១គ្រឿង

៥-ប្រដាប់ប្រើប្រាស់គ្រឿងញៀនមួយចំនួន

គប្បីតុលាការពិនិត្យពិចារណាសម្រេចរឹបអូស តាមបញ្ញត្តិមាត្រា ៦២ , ៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**យល់ឃើញថា**

-ដីកាបង្គាប់ឲ្យតម្កល់វត្ថុតាងលេខ ៩២០១ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ បានច្រកចូលក្នុងកញ្ចប់វត្ថុតាងលេខ <u>KS ០០៤៤៧២</u> មានចំនួន ០២ កញ្ចប់ ទម្ងន់ចំនួន ០,៦៤ ក្រាម គប្បីតុលាការពិនិត្យពិចារណាសម្រេច ។

**យល់ឃើញថា**

-ជនជាប់ចោទឈ្មោះ [redacted] នុន ហៅលេញ ,ឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ និង ឈ្មោះ [redacted] ប៊ុនធឿន ហៅ ប៊ិ នាពេលសវនាការសុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន គប្បីតុលាការពិនិត្យពិចារណាក្នុងការសម្រេចសេចក្តី ។



Scanned with CamScanner

**សាលាដំបូងខេត្តកំពង់ស្ពឺ**
**<u>វិនិច្ឆ័យសេចក្តី</u>**

១/ -**<u>ផ្តន្ទាទោសលើជនជាប់ចោទ៖</u>**

**១.១-ឈ្មោះ [redacted]ខុន ហៅ លេញ** ភេទប្រុស អាយុ ២៥ឆ្នាំ (មានសាវតាជាតិ ដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន **០២(ពីរ)ឆ្នាំ** និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០៛ (បួនលាន) រៀល សម្រាប់បង់ចូលថវិការរដ្ឋ ។

**១.២-ឈ្មោះ [redacted]ចំរើន ហៅ ម៉ាប់** ភេទប្រុស អាយុ ៣០ឆ្នាំ (មានសាវតាជាតិ ដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន **០២(ពីរ)ឆ្នាំ** តែទោសអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេលចំនួន **១៨ (ដប់ប្រាំបី)** ខែ ឯទោសនៅសល់ព្យួរធម្មតា ។

**<u>ពីបទ៖</u>** រក្សាទុក ឬ ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិអូររំចេក ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០,៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

២/ -**<u>ផ្តន្ទាទោសលើជនជាប់ចោទ៖</u>**

-ឈ្មោះ **[redacted] ម៉ុនធឿន ហៅ ម៉ិ** ភេទប្រុស អាយុ ២៤ឆ្នាំ (មានសាវតាជាតិ ដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល **០២(ពីរ)ឆ្នាំ** តែទោសអនុវត្តក្នុងពន្ធនាគារកំណត់រយៈចំនួន **០៧(ប្រាំពីរ)** ខែ ឯទោសនៅសល់ព្យួរធម្មតា ។

**<u>ពីបទ៖</u>** រក្សាទុក និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិអូររំចេក ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ , ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

៣/ -**<u>ផ្តន្ទាទោសលើជនជាប់ចោទ៖</u>**

-ឈ្មោះ **[redacted] ជាតិ** ភេទប្រុស អាយុ ២៥ ឆ្នាំ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន**០៣(បី)ឆ្នាំ** គិតពីថ្ងៃចាប់ខ្លួនបាន និង ពិន័យជាប្រាក់ចំនួន ៤.០០០.០០០៛ (បួនលាន) រៀល សម្រាប់បង់ចូលថវិការរដ្ឋ ។

**<u>ពីបទ៖</u>** រក្សាទុក ឬ ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិអូររំចេក ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០,៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៤/**-ចេញដីកាបង្គាប់ឲ្យចាប់ និង ឃុំខ្លួន លើពិរុទ្ធជនឈ្មោះ **[redacted] ជាតិ** ភេទប្រុស អាយុ ២៥ ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិ) តាមបញ្ញត្តិមាត្រា **៣៥៣** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned with CamScanner

៥/-**វត្ថុតាងរួមមាន៖**

៥.១-ទូរស័ព្ទដៃ០១គ្រឿងម៉ាក VIVO ពណ៌ក្រហម , ទូរស័ព្ទដៃ០១គ្រឿងម៉ាក HVAWEI ពណ៌ទឹកប្រាក់ និង ម៉ូតូ ០១គ្រឿង ម៉ាកគុបជ្រុង ពណ៌ទឹកប៊ិច ពាក់ស្លាកលេខ ជ.០២៦៩ ភព១ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

៥.២-ជញ្ជីងថ្លឹងគ្រឿងញៀនចំនួន០១គ្រឿង,ប្រដាប់ប្រើប្រាស់គ្រឿងញៀនមួយចំនួន និង គ្រឿងញៀនប្រភេទម៉ាទឹកកក ចំនួន០២កញ្ចប់ ទម្ងន់ចំនួន០,៦៤ ក្រាម ត្រូវរឹបអូសបំផ្លាញចោល។

៦/-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២០ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែ មករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] នុន ហៅ លេញ ,ឈ្មោះ [redacted] ចំរើន ហៅ ម៉ាប់ ,ឈ្មោះ [redacted] ប៊ុនធឿន ហៅ ប៊ុ និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ជាតិ ។

-ទុកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

[redacted] [redacted]